**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៩៣ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារសិក្សាអំពីសង្គតិភាព រវាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងបទប្បញ្ញត្តិច្បាប់ស្តីពីសារពើពន្ធ

៣៣៣៛៤៤៤

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/ ០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- បានឃើញព្រះរាជក្រម លេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦០៩/០៨ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ២៧ សសរ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន
- ស្មារតីនៃកិច្ចប្រជុំក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និង អភិបាលកិច្ច (ក្រុម «ឃ») នៃវេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩
- បានឃើញលិខិតចាត់បញ្ជូនរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ ១:** បង្កើតក្រុមការងារសិក្សាអំពីសង្គតិភាព រវាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងបទប្បញ្ញត្តិច្បាប់ស្តីពីសារពើពន្ធ ដែលស្ថិតក្រោមក្របខ័ណ្ឌ នៃក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និង អភិបាលកិច្ច (ក្រុម «ឃ») នៃវេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន ។

**ប្រការ ២:** ក្រុមការងារសិក្សាអំពីសង្គតភាព រវាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងបទប្បញ្ញត្តិច្បាប់ស្តីពីសារពើពន្ធ មានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ចាន់ ឌួន ឈារ៉ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម | **ស៊ឹម អឿន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្តម | **កើត រិទ្ធ** | អនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤- លោកស្រី | **ខួន សុខា** | អគ្គនាយករងនៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៥- លោក | **ឌួច ថារិទ្ធិ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី | សមាជិក |
| ៦- លោស្រី | **សួរ ស្រីម៉ិច** | អនុប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- តំណាងលោកសហប្រធានក្រុម «ឃ» | | | សមាជិក |
| ៨- លោក | **ទ៉ាន់ ពុទ្ធិពល** | ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩- លោក | **ឡុង សេង** | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១០- លោក | **ម៉ែម ធារសនា** | ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១១- លោក | **ថូ ចំនួនតារ៉ូ** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២- លោកស្រី | **ម៉ែន សុបតា** | អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |

១៣- លោក **សេង រតនា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ — សមាជិក

១៤- លោក **ស្រ៊ុន អង្គរ៉េន** ប្រធានការិយាល័យសវនកម្មសហគ្រាសធំ នៃអគ្គនាយកដ្ឋានពន្ធដារ — សមាជិក

១៥- លោក **លឹម ពិនិត្យ** អនុប្រធានការិយាល័យនៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក

**ប្រការ ៣:** ក្រុមការងារសិក្សាអំពីសង្គតិភាព រវាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងបទប្បញ្ញត្តិច្បាប់ស្តីពីសារពើពន្ធ មានភារកិច្ចដូចខាងក្រោម ÷

- សិក្សា និង ពន្យល់ អំពីសង្គតិភាព និង ភាពមិនស្របគ្នា រវាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងបទប្បញ្ញត្តិច្បាប់ស្តីពីសារពើពន្ធ ។
- រៀបចំសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ និង លិខិតបទដ្ឋាននានា ដើម្បីសម្រួលដល់ការអនុវត្តច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធនឹងបទប្បញ្ញត្តិច្បាប់ស្តីពីសារពើពន្ធ ។
- ត្រូវរាយការណ៍អំពីលទ្ធផលនៃការងារ ជូនក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច (ក្រុម «ឃ») នៃវេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន ឱ្យបានជាប់ជាប្រចាំ ។

**ប្រការ ៤:** អនុប្រធាន និងសមាជិក ត្រូវចូលរួមការប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានប្រចាំការ ដើម្បីដឹកនាំការងារជំនួស ក្នុងករណីមានធុរៈជាយថាហេតុ ។

**ប្រការ ៥:** ឯកឧត្តមរដ្ឋលេខាធិការ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

***កន្លែងទទួល:***
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *រាជកិច្ច*